# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៨១២ អក-៩៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការចុះបំផុសស្មារតីច្បាប់ តាមខេត្ត-ក្រុង និងជនបទរបស់គណៈមេធាវី ។

**យោង:** លិខិតលេខ ២៤៧ គម-៩៦ ចុះថ្ងៃទី០១-០៧-៩៦ របស់ឯកឧត្តម ។

ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ក្រសួងយុត្តិធម៌បានទទួលលិខិតដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើរបស់ឯកឧត្តមស្តីពីការចុះបំផុសស្មារតីច្បាប់ តាមខេត្ត ក្រុង ជនបទ និងចូលរួមជួបជនជាប់ចោទ ជនត្រូវឃាត់ខ្លួនឃុំឃាំងក្នុងពន្ធនាគារខេត្ត-ក្រុង ។ ស្មារតីបំផុសប្រជាពលរដ្ឋអោយយល់អំពីច្បាប់នេះក្រសួងយុត្តិធម៌សូមគាំទ្រនិងឯកភាពទាំងស្រុងចំពោះការចូលរួមជួបទណ្ឌិត និងពិរុទ្ធជននៅតាមមន្ទីរឃុំឃាំង និងពន្ធធាគារខេត្ត-ក្រុង ដើម្បីធ្វើការអប់រំផ្សព្វផ្សាយច្បាប់ និងស្វែងយល់អំពីស្ថានភាពជីវិភាពរស់នៅរបស់អ្នកទាំងនោះ ។ សូមឯកឧត្តមសហការជាមួយព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ហើយមិនគួរគប្បីចុះសួរយកចម្លើយ ឬធ្វើសម្ភាសន៍ដល់ពិរុទ្ធជន ឬទណ្ឌិត ដោយគ្មានការអនុញ្ញាតយល់ព្រមពីព្រះរាជរាជ្ញាឡើយ ។

សូមលោកប្រធានទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
-តុលាការ និងអយ្យការខេត្ត ក្រុង
-ដើម្បីជ្រាប និងសហការ